ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករគណនេយ្យនិងសវនកម្ម

លេខ..០០៦/២៣.........ន. គ. ស /.ស.ន.ក.

ថ្ងៃ មង្គល ១០កើត៣ ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែ មករា ឆ្នាំ២០២៣

**សេចក្តីជូនដំណឹង**

**ស្តីពីការត្រួតពិនិត្យអនុលោមភាពតាម "ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និង ច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ"**

**និយ័តករគណនេយ្យនិងសវនកម្ម** (ន.គ.ស.) នៃ **អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** សូមជម្រាបជូនដំណឹងដល់ **លោក លោកស្រី អ្នកនាង កញ្ញាប្រធានក្រុមហ៊ុនគណនេយ្យ និងក្រុមហ៊ុនសវនកម្ម** ទាំងអស់ មេត្តាជ្រាបថា÷ **ន.គ.ស.** នឹងធ្វើការចុះត្រួតពិនិត្យលើអនុលោមភាពតាម **"ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ"** ដល់ទីកន្លែង របស់ក្រុមហ៊ុន ស្របពេលគ្នានឹងធ្វើការត្រួតពិនិត្យគុណភាពសវនកម្មសម្រាប់ឆ្នាំ២០២៣ ដែលគ្រោងនឹងប្រព្រឹត្តទៅចាប់ពី**ខែកក្កដា ឆ្នាំ២០២៣** តទៅនេះ។

ការចុះត្រួតពិនិត្យដល់ទីកន្លែងនេះ ត្រូវធ្វើឡើងស្របតាមមាត្រា៤ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម (ព្រះរាជក្រមលេខ នស/រកម/០៦២០/០២១ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០) និងមាត្រា១១ នៃច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (ព្រះរាជក្រមលេខ នស/រកម/០៦២០/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០) ដែលបានកំណត់ថា ក្រុមហ៊ុនគណនេយ្យ និងក្រុមហ៊ុនសវនកម្ម គឺជាបុគ្គលរាយការណ៍ក្នុងវិស័យគណនេយ្យនិងសវនកម្ម នៅព្រះរាជាណាចក្រកម្ពុជា។

គោលបំណងនៃការចុះត្រួតពិនិត្យលើការអនុលោមភាពតាមច្បាប់ទាំង២ នេះ ដើម្បីបង្ការ ទប់ស្កាត់ បង្ក្រាប និងលុបបំបាត់នូវរាល់សកម្មភាពជាប់ពាក់ព័ន្ធនឹងការសម្អាតប្រាក់, ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពសម្រាប់វិស័យគណនេយ្យនិងសវនកម្មក្នុងព្រះរាជាណាចក្រកម្ពុជា។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោក លោកស្រី អ្នកនាង កញ្ញាប្រធានក្រុមហ៊ុនគណនេយ្យ និងក្រុមហ៊ុនសវនកម្ម** ទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។

**និយ័តករគណនេយ្យនិងសវនកម្ម**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ ០៥៥ - ២៣ ៨៨២ ១១១
Phone: 023 882 111